# ព័ត៌មានថ្មីៗ

## Leon Bignell MP

រដ្ឋមន្ត្រីក្រសួងកសិកម្ម ស្បៀងអាហារ និងនេសាទ

ថ្ងៃអង្គារ៍ ទី១១ ខែតុលា ឆ្នាំ២០១៦

**ជំនួយកាន់តែច្រើនរបស់រដ្ឋាភិបាលប្រចាំរដ្ឋ សម្រាប់ពលរដ្ឋអូស្ត្រាលីខាងត្បូងដែលបានរងប៉ះពាល់ដោយទឹកជំនន់**

រដ្ឋាភិបាលប្រចាំរដ្ឋនឹងផ្តល់ការផ្គត់ផ្គង់បន្ថែមទៀត ទៅដល់អ្នកផលិតវត្ថុធាតុដើមដែលបានរងប៉ះពាល់ដោយទឹកជំនន់នៅតាមតំបន់ទំនាបនៅទន្លេ Gawler River ដោយមានប្រាក់ឧបត្ថម្ភហូតដល់ទៅ $10,000។

បន្ថែមទៅនឹងប្រាក់ឧបត្ថម្ភនេះ កងកម្លាំងមួយនឹងបានបង្កើតឡើងដើម្បីបំពេញមុខការលើការងើបឡើងវិញផ្នែកសេដ្ឋកិច្ចរយៈពេលវែង ដើម្បីជួយដល់អាជីវកម្មដែលបានរងប៉ះពាល់ពេញទូទាំងរដ្ឋអភិវឌ្ឍឱកាសវិនិយោគនាពេលអនាគត។

រដ្ឋមន្ត្រីក្រសួងកសិកម្មលោក Leon Bignell នឹងជាប្រធានកងកម្លាំងឧស្សាហកម្មពាណិជ្ជកម្មការធ្វើវិនិយោគឡើងវិញផ្នែកអាជីវកម្ម ហើយលោកហិរញ្ញិក Tom Koutsantonis នឹងជាអនុប្រធាន។ សមាជិកដទៃទៀតរួមមានលោករដ្ឋមន្ត្រី Stephen Mullighan និងលោករដ្ឋមន្ត្រី Kyam Maher ព្រមទាំងតំណាងឧស្សាហកម្មមួយចំនួនទៀតដែរ។

ការផ្តោតអារម្មណ៍នៃកងកម្លាំងនេះនឹងទៅលើការប្រើប្រាស់ឱកាសវិនិយោគឡើងវិញផ្នែកអាជីវកម្ម ដើម្បីបង្កើតឡើងវិញ និងការរីកលូតលាស់អាជីវកម្មផលិតវត្ថុធាតុដើមដែលបានរងប៉ះពាល់ដោយខ្យល់ព្យុះ និងទឹកជំនន់។

បន្ទាប់មក រដ្ឋាភិបាលប្រចាំរដ្ឋនឹងផ្តល់ការផ្គត់ផ្គង់ថវិកាបន្ថែមទៀត កន្លែងណាដែលសមស្រប។

**សម្រង់ចេញពីរដ្ឋមន្ត្រីក្រសួងកសិកម្ម ស្បៀងអាហារ និងនេសាទ លោក Leon Bignell**

វិស័យកសិកម្មរដ្ឋរបស់យើងត្រូវបានរងប៉ះពាល់យ៉ាងខ្លាំងដោយខ្យល់ព្យុះ និងទឹកជំនន់ក្នុងពេលថ្មីៗនេះ - ជាពិសេស នៅតាមតំបន់ទំនាបនៅទន្លេ Gawler River។

ខ្ញុំបានទៅពិនិត្យមើលតំបន់កាលពីសប្តាហ៍មុននេះ ហើយខ្ញុំបានឃើញការខូចខាតជាលើកដំបូង ហើយខ្ញុំក៏បានទៅទីនោះម្តងទៀតនៅថ្ងៃនេះ ដើម្បីប្រកាសពីការឆ្លើយតបរបស់យើងចំពោះដំណាក់កាលបន្ទាប់នៃការងើបឡើងវិញ។

នៅឆ្នាំ២០០៥ ពេលកើតមានទឹកជំនន់ សហគមន៍ និងអ្នកជាំផុះក្នុងតំបន់បាននាំគ្នាប្រុងប្រៀបដើម្បីគ្រប់គ្រងការខូចខាតដោយខ្លួនឯង។ ជាអកុសល គឺវាត្រូវការពេលរាប់ខែទំរាំតែទឹកហូរស្ងួតវិញ ហើយដំណើរការនោះបណ្តាលឱ្យកើតមានការម៉ួរម៉ៅក្នុងចំណោមមនុស្សទាំងឡាយដែលបានទទួលការតានតឹងចិត្តរួចហើយដោយសារទឹកជំនន់។

ពេលនេះ រដ្ឋាភិបាលប្រចាំរដ្ឋបានចាត់វិធានការទាន់ពេលដើម្បីផ្តល់នូវភាពជាអ្នកដឹកនាំ និងការសម្របសម្រួល។

ស្ទើរតែភ្លាមៗនោះ យើងមានក្រុមមកពី PIRSA ដើម្បីវាយតម្លៃការខូចខាត និងផ្តល់ដំបូន្មានដល់អាជីវកម្ម។ រដ្ឋាភិបាលប្រចាំរដ្ឋក៏បានបង្កើតឱ្យមានទូរស័ព្ទទាន់ហេតុការណ៍ដែរ - ដែលបានជួយអ្នកហៅច្រើនជាង៤០នាក់ - ហើយមានអ្នកផលិតចំនួន៧៦នាក់ដែលបានរងប៉ះពាល់ បានបញ្ចប់ការវាយតម្លៃលើការរងប៉ះពាល់។

ប្រាក់ឧបត្ថម្ភចំនួន $10,000 គឺបន្ថែមទៅលើកងកម្លាំងឧស្សាហកម្មពាណិជ្ជកម្មការធ្វើវិនិយោគឡើងវិញផ្នែកអាជីវកម្ម ដែលនឹងពិនិត្យមើលវិធីដែលអាជីវកម្ម និងឧស្សាហកម្មដែលរងប៉ះពាល់ដោយទឹកជំនន់ ឆ្លងកាត់ខ្យល់ព្យុះនេះដែលមានសភាពធ្ងន់ធ្ងរជាងមុន។

កងកម្លាំងនឹងធ្វើការជាមួយអាជីវកម្ម និងអ្នកដឹកនាំសហគមន៍ដើម្បីនឹកគិតអំពីដំណោះស្រាយរយៈពេលវែង។

ទំនាក់ទំនងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន៖ Simonne Reid 0400 650 951

សម្រាប់កសិករជាច្រើន វាអាចចំណាយពេលពីប្រាំមួយខែ ទៅ១២ខែដើម្បីងើបឡើងវិញ។ រដ្ឋាភិបាលប្រចាំរដ្ឋនឹងនៅប្រចាំការទីនេះ សម្រាប់រយៈពេលវែង ខិតខំប្រឹងប្រែងធ្វើការដើម្បីជួយនាំពួកឱ្យអាចងើបឈរឡើងវិញ។

**ផ្ទៃរឿង**

ខ្យល់ព្យុះក្នុងពេលថ្មីៗនេះ ដែលបំផ្លិចបំផ្លាញយ៉ាងខ្លាំងក្លាបំផុតក្នុងរដ្ឋអូស្ត្រាលីខាងត្បូងអស់រយៈពេលជាង៥០ឆ្នាំមកហើយ ជាមួយនឹងទឹកជំនន់ដែលទាក់ទិនរវាងខែកញ្ញា ទី២៨ និងខែតុលា ទី៤ បណ្ដាលឱ្យខូចខាតយ៉ាងដំណំដល់អាជីវកម្មផលិតកម្មវត្ថុធាតុដើម។

ឧស្សាហកម្មប៉ាន់ប្រមាណថាមានអ្នកដាំដុះរហូតដល់ទៅ៣០០នាក់ ត្រូវបានរងប៉ះពាល់ដោយទឹកជំនន់ - នៅក្នុងករណីខ្លះទៀត ទឹកជំនន់ឡើងរហូតដល់ទៅពីរម៉ែត្រ លេចពាសពេញវាលស្រែចំការ និងពេញទូទាំងអាគារកញ្ចក់របស់ពួកគេ។

រដ្ឋាភិបាលបានផ្ដត់ផ្គង់ថវិកា $260,000 រួចហើយ ដើម្បីជួយបូមទឹកជំនន់ចេញពីដីចំការ ចូលទៅទន្លេ Gawler River វិញ។

ប្រាក់ឧបត្ថម្ភបន្ថែមចំនួន $10,000 នឹងមានផ្ដល់សម្រាប់អាជីវកម្មទាំងឡាយដែលមានសិទ្ធិទទួលក្នុងតំបន់ទឹកជំនន់តាមតំបន់ទឹកលេចនៅទន្លេ Gawler River - រួមមានសាលាក្រុង Adelaide Plains - ដើម្បីជួយជាមួយនឹងការចំណាយភ្លាមៗទាក់ទិននឹងការខូចខាតដោយទឹកជំនន់ និងខ្យល់ព្យុះ។

ព័ត៌មាន និងគោលការណ៍ណែនាំស្ដីពីរបៀបដាក់ពាក្យសុំប្រាក់ឧបត្ថម្ភ មានផ្ដល់ជូននៅតាមវិបសាយរបស់ Primary Industries and Regions SA (PIRSA) (ក្រសួងឧស្សាហកម្មវត្ថុធាតុដើម និងតំបន់ភូមិភាគ) នៅត្រង់ www.pir.sa.gov.au/gawlerriverfloodplaingrants

អ្នកផលិតវត្ថុធាតុដើមដែលត្រូវការជំនួយ គួរទូរស័ព្ទទៅខ្សែទូរស័ព្ទទាន់ហេតុការណ៍របស់ PIRSA លេខ (08) 8207 7847។

ក្រុម PIRSA នឹងប្រតិបត្តិការពីមជ្ឈមណ្ឌលសាកវប្បកម្មរដ្ឋ Virginia សម្រាប់ពេលអនាគតឆាប់ៗខាងមុខនេះ។